# មេរៀនទី ៣០: ការអ៊ីនសម្លាប់អេបិល

## លោកុប្បត្តិ ៤:១-១៦

**គោលបំណង៖** ព្រះស័ក្តិសមនឹងទទួលរបស់ល្អបំផុតរបស់យើង។

**ខគម្ពីរចងចាំ៖ រ៉ូម ១១:៣៦** *"ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសំរាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះបានបង្រៀនយើងអំពីសេចក្តីស្រឡាញ់តាមរយៈជីវិតរបស់ព្រះយេស៊ូវ និងតាមរយៈគ្រួសាររបស់យើង។ តើព្រះបានបង្រៀនយើងអំពីសេចក្តីស្រឡាញ់តាមរយៈគ្រួសាររបស់អ្នកដោយរបៀបណា? សូមចំណាយពេលខ្លះដើម្បីសរសេរលិខិតខ្លីផ្ញើទៅសមាជិកគ្រួសាររបស់អ្នក ដើម្បីបង្ហាញថាព្រះស្រឡាញ់អ្នកតាមរយៈពួកគេយ៉ាងដូចម្តេច ហើយបង្ហាញក្តីស្រឡាញ់របស់អ្នកទៅកាន់ពួកគាត់គ្រប់គ្នាវិញផងដែរ។ ក៏សូមចំណាយពេលអធិស្ឋានសម្រាប់គ្រួសារសិស្សរបស់អ្នក ហើយទូលសូមព្រះឲ្យជួយសិស្សរបស់អ្នករៀនពីព្រះបន្ថែមទៀតតាមរយៈក្រុមគ្រួសាររបស់ពួកគេ។

**ចំរៀង៖** ១. តើអ្នកណាជាម្ចាស់នៃខ្ញុំ ២.ហូសាណានៅស្ថានខ្ពស់បំផុត ៣. ខ្ញុំថ្វាយបង្គំទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «បញ្ជូនបាល់»**

**សម្ភារៈដែលត្រូវការ៖** កែវជ័រធំ៦ ស្លាបព្រា១០ និងបាល់តូច៦




១. ចែកុមារជាពីរក្រុមដែលមួយក្រុមទទួលបាន កែវ ៣ ស្លាបព្រា ៥ និងបាល់តូចៗ ៣ ហើយដាក់នៅលើតុសម្រាប់ក្រុមនីមួយៗ

២. ឲ្យក្រុមនីមួយៗ រើសតំណាងក្រុម៣នាក់មកកាន់តុ។ កុមារទី១ត្រូវយកបាល់មួយមកដាក់ក្នុងស្លាបព្រា ទី១។ ហើយគេត្រូវជញ្ជូនបាល់នោះដោយមិនឲ្យជ្រុះនោះទេ។ ដោយបញ្ជូនបាល់នោះបន្តបន្ទាប់រហូតដល់ស្លាបព្រាទី៥ ហើយប្រើស្លាបព្រាចុងក្រោយ យកបាល់ទៅដាក់ក្នុងកែវទី១។

៣. កុមារទី ២នឹងឡើងមកហើយលេងដូចកុមារទី១ដែរ។ ក្រុមណាដែលអាចយកបាល់ដាក់ចូលទៅក្នុងកែវបានគ្រប់៣មុន ក្រុមនោះជាអ្នកឈ្នះ។



៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកគេបានព្យាយាមអស់ពីសមត្ថភាពក្នុងការលេងល្បែងនេះ ពីព្រោះព្រះស័ក្តិសមទទួលបាននូវអ្វីដែលល្អបំផុតពីយើង។

## ៤. ការណែនាំមេរៀន

បើសិនអ្នកមានរបស់ចាស់មួយ និងរបស់ថ្មីមួយ តើមួយណាដែលអ្នកយកទៅថ្វាយព្រះ? ព្រះតែងតែប្រទានឲ្យយើងនូវអ្វីដែលល្អបំផុត ដូច្នេះយើងត្រូវតែប្រទានអ្វីដែលល្អបំផុតដែលយើងមានថ្វាយទៅទ្រង់វិញផងដែរ។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលបានជួបនឹងបញ្ហាពីព្រោះតែគាត់មិនបានគិតថាការដែលត្រូវថ្វាយរបស់ល្អបំផុតដែលគាត់មានទៅកាន់ព្រះជាម្ចាស់ជារឿងសំខាន់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះដកស្រង់ពីព្រះគម្ពីរលោកុប្បត្តិ។ យើងបានដឹងថាបន្ទាប់ពីព្រះបានបង្កើតផែនដីហើយ ព្រះអង្គបានបង្កើតអ័ដាម និងអេវ៉ាដើម្បីរស់នៅលើផែនដីនេះ។ អ័ដាម និងអេវ៉ាមិនបានស្តាប់បង្គាប់ព្រះហើយត្រូវចាកចេញពីសួនច្បារអេដែន។ ក្រោយមកអេវ៉ាមានកូនប្រុសម្នាក់ ហើយបានដាក់ឈ្មោះថា កាអ៊ីន។ ក្រោយមកនាងក៏មានកូនម្នាក់ទៀតជាប្អូនប្រុសរបស់កាអ៊ីនហើយគេដាក់ឈ្មោះថា អេបិល! នៅពេលដែលក្មេងប្រុសទាំង២នេះបានធំឡើង កាអ៊ីនបានក្លាយជាកសិករដាំបន្លែ ចំណែកអេបិលក្លាយជាអ្នកគង្វាលចៀម។

កាអ៊ីនបានប្រឹងធ្វើការនៅក្នុងចំការរបស់គាត់។ គាត់បានស្រោចទឹកដំណាំ និងបោចស្មៅផងដែរ។ ចំណែកអេបិ-លបានប្រឹងប្រែងធ្វើការថែទាំចៀមរបស់គាត់។ គាត់ត្រូវប្រាកដថាចៀមគាត់មានស្មៅខ្ចីស៊ី និងមានទឹកត្រជាក់ផឹក។ ថ្ងៃមួយកាអ៊ីន និងអេបិលបានយកតង្វាយរបស់ខ្លួនទៅថ្វាយព្រះ។ អេបិលបានថ្វាយរបស់ល្អបំផុតដែលគាត់អាចរកបាននៅក្នុងហ្វូងចៀមរបស់គាត់ថ្វាយទៅព្រះ ហើយព្រះសព្វព្រះទ័យខ្លាំងណាស់។ ប៉ុន្តែកាអ៊ីនមិនបានថ្វាយរបស់ដែលល្អបំផុតពីចំការរបស់គាត់ទៅព្រះទេ។ ព្រះមិនសព្វព្រះទ័យជាមួយកាអ៊ីនទេ ពីព្រោះអ្វីដែលព្រះចង់បានមិនមែនបន្លែដែលល្អបំផុតដែលកាអ៊ីនមានទេ ប៉ុន្តែអ្វីដែលព្រះចង់បាននោះគឺបេះដូងដ៏ល្អបំផុតរបស់កាអ៊ីនថ្វាយដល់ព្រះ។ កាអ៊ីនបានច្រណែនដែលអេបិលធ្វើអ្វីដែលត្រូវ។ ជំនួសឲ្យការនិយាយសូមទោសចំពោះព្រះ កាអ៊ីនបែរជាខឹងទៅវិញ។

កាអ៊ីនអាចនឹងនិយាយថា គាត់សុំទោសហើយព្រះអាចនឹងអត់ទោសឲ្យគាត់។ កាអ៊ីនអាចរៀបចំតង្វាយផ្សេងទៀតជាមួយនឹងក្តីស្រឡាញ់ថ្វាយទៅព្រះជំនួសឲ្យការខឹងជាមួយនឹងប្អូនប្រុសរបស់គាត់។ ផ្ទុយទៅវិញ កាអ៊ីនបានសំរេចចិត្តមកសងសឹកអេបិលដែលធ្វើឲ្យគាត់មើលទៅអាក្រក់ជាងមុនទៅទៀត។ ដូច្នេះកាអ៊ីនបានសម្លាប់ប្អូនប្រុសរបស់គាត់ បន្ទាប់មកកាអ៊ីនបានជួបទុក្ខលំបាកកាន់តែច្រើន។ មិនត្រឹមតែមិនបានថ្វាយតង្វាយដែលល្អបំផុតដែលគាត់មានថ្វាយទៅព្រះទេ តែគាត់ថែមទាំងធ្វើឲ្យអ្នកដទៃដែលថ្វាយតង្វាយដែលល្អ ហើយស្មោះស្ម័គ្របំផុតឈឺចាប់ទៅវិញ។

ព្រះស័ក្តិសមនឹងទទួលនូវតង្វាយដ៏ល្អបំផុត ពីព្រោះព្រះអង្គស្រឡាញ់យើងខ្លាំងណាស់! តង្វាយដែលល្អបំផុតដែលយើងអាចថ្វាយទៅព្រះគឺដួងចិត្តរបស់យើង។ គឺមានន័យថាយើងស្រលាញ់ព្រះជាខ្លាំង ហើយយើងនឹងថ្វាយអ្វីដែលល្អជាងគេដល់ទ្រង់។

## ៦. សំនួរពិភាក្សា

១. តើកូនប្រុសពីរនាក់របស់អ័ដាម និងអេវ៉ាមានឈ្មោះអ្វី? *កាអ៊ីន និងអេបិល*

២. តើការងាររបស់ពួកគេជាអ្វី? *កាអ៊ីនជាកសិករ ហើយអេបិលជាអ្នកគង្វាល*

៣. ហេតុអ្វីព្រះមិនសប្បាយចិត្តនឹងតង្វាយរបស់កាអ៊ីន? *ដោយសារកាអ៊ីនមិនបានថ្វាយអ្វីល្អបំផុត ដែលគាត់មាន ដែលបង្ហាញពីចិត្តរបស់គាត់មិនពេញដោយសេចក្ដីស្រឡាញ់ចំពោះព្រះ*

៤. តើអ្នកអាចថ្វាយអ្វីដែលល្អបំផុតដែលអ្នកមានដោយរបៀបណា? *សូមឲ្យកុមារឆ្លើយ សរសើរដំកើងព្រះដោយសំឡេងខ្លាំងៗ អធិស្ឋានទៅព្រះដោយដឹងថាព្រះនឹងឆ្លើយតប ថែរក្សាមនុស្សដែលខ្វះខាត ។ល។*

## ៧. ល្បែងកំសាន្ត «បោះបាល់ចូលកែវ»



**សម្ភារៈដែលត្រូវការ៖** កែវប្លាស្ទិក ឬកែវក្រដាសចំនួន៣ កូនបាល់ តុ ស្កុត

១. ចែកកុមារជា៣ ក្រុមហើយឲ្យពួកគេឈរជាជួរ

២. បិតកែវទាំង ៣ ភ្ជាប់ជាគែមតុ ហើយត្រូវកំណត់ថាកែវណាសម្រាប់ក្រុមមួយណា

៣. ក្រុមនីមួយៗ ត្រូវព្យាយាមមៀលបាល់នោះចូលទៅក្នុងកែវរបស់ពួកគេ ដើម្បីទទួលបានពិន្ទុ។ ប្រសិន បើបាល់ចូលទៅក្នុងកែវរបស់ក្រុមផ្សេងនោះគេមិនទទួលបានពិន្ទុនោះទេ។ ក្រុមណាដែលទទួលបានពិន្ទុ ច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។




៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មានកិច្ចការជាច្រើនដែលយើងអាចធ្វើបានដើម្បីថ្វាយទៅព្រះ។ ប៉ុន្តែយើងត្រូវតែធ្វើដូចជាអេបិល ហើយថ្វាយព្រះនូវអ្វីដែលល្អបំផុតដែលយើងមានដោយអស់អំពីចិត្ត។

## ៨. ខគម្ពីរចងចាំ រ៉ូម ១១:៣៦

## ៩. ហត្ថកម្ម «ព្រះជាម្ចាស់ស័ក្តិសមនឹងទទួលបានអ្វីដែលល្អបំផុតពីយើង»



**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម, កូល័រ, កន្ត្រៃ, ការបិត

១. ចែកក្រដាសហត្ថកម្មដែលបានបោះពុម្ពរួចដល់កុមារម្នាក់១សន្លឹក ហើយឱ្យពួកគេផាត់ពណ៌ក្រដាសហត្ថកម្មនោះ។

២. ឱ្យពួកគេកាត់ រូបកាអ៊ីន និង រូបអេបិល។ សូមឲ្យកុមារបិទរូបអេបិលនៅខាងក្រោយអាសនាដែលមានរូបបេះដូង ដើម្បីជានិមិត្តរូបថាព្រះសព្វព្រះហឫទ័យនឹងតង្វាយរបស់អេបិល។ សូមឲ្យកុមារបិតរូបកាអ៊ីននៅ ខាងក្រោយអាសនាដែលគ្មានរូបបេះដូង ដើម្បីជានិមិត្តរូបថាព្រះមិនពេញចិត្តនឹងតង្វាយរបស់កាអ៊ីន។

៣. ពន្យល់ដល់កុមារថា ព្រះស័ក្តិសមនឹងទទួលបានរបស់ល្អបំផុតរបស់យើង ហើយទ្រង់តែងតែចង់ឱ្យបេះដូងរបស់យើងពេញដោយសេចក្ដីស្រឡាញ់ចំពោះទ្រង់។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះស័ក្តិសមនឹងទទួលបានរបស់ល្អបំផុតពីយើង







១. ចែកក្រដាសហត្ថកម្មដែលបានបោះពុម្ពរួចដល់កុមារម្នាក់១សន្លឹក ហើយឱ្យពួកគេផាត់ពណ៌ក្រដាសហត្ថកម្មនោះ។
២. ឱ្យពួកគេកាត់ រូបកាអ៊ីន និង រូបអេបិល។ សូមឲ្យកុមារបិទរូបអេបិលនៅខាង ក្រោយអាសនាដែលមានរូបបេះដូង ដើម្បីជានិមិត្តរូបថាព្រះសព្វព្រះហឫទ័យនឹងតង្វាយរបស់អេបិល។ សូមឲ្យកុមារបិតរូបកាអ៊ីននៅ ខាងក្រោយអាសនាដែលគ្មានរូបបេះដូង ដើម្បីជានិមិត្តរូបថាព្រះមិនពេញចិត្តនឹងតង្វាយរបស់កាអ៊ីន។